# សិក្ខាសាលាស្តីអំពីផែនការយុទ្ធសាស្ត្រ ២០០៩-២០១៣
# ដើម្បីបំរើបំរួលជនបទនៅកម្ពុជា

នៅថ្ងៃទី ១-៣ ខែកក្កដា ឆ្នាំ ២០០៩ សេដាក បានរៀបចំ សិក្ខាសាលាស្តីអំពី**ផែនការយុទ្ធសាស្ត្រ ២០០៩-២០១៣ ដើម្បី បំរើបំរួលជនបទនៅកម្ពុជា** នៅណ្ឌាគារឆ្នេរសមុទ្រ ខេត្តព្រះសីហនុ។ បុគ្គលិកសេដាក សំខាន់ៗចំនួន ៤៣ នាក់ (ស្ត្រី ១០ នាក់) បានចូលរួមនៅក្នុងសិក្ខាសាលានេះ។ សិក្ខាសាលានេះឧបត្ថមដោយមូលនិធិហ្វ្រីឌ្រិចណៅម៉ាន់ ដើម្បីសេរីភាព (FNS)។ គោលបំណងសំខាន់នៃសិក្ខាសាលានេះគឺដើម្បីៈ

- ឆ្លុះបញ្ចាំងពីនិន្នាការកន្លងមករបស់ សេដាក (ទាំងវិជ្ជមាន និងអវិជ្ជមាន) ហើយនិងបទពិសោធន៍ដែលទទួលបាន
- វិភាគអំពីចំនុចខ្លាំង ចំនុចខ្សោយ ឱកាស និងកត្តាគំរាមកំហែង នៃស្ថានភាពបច្ចុប្បន្នរបស់ សេដាក ដើម្បីបង្កើនឱកាសបន្ថែមទៀតសម្រាប់ សេដាក
- កំណត់នូវអ្វីដែលត្រូវបន្តធ្វើ កែតម្រូវ ពង្រឹងបន្ថែម និងបញ្ឈប់សម្រាប់ឆ្នាំ ២០១៣

នៅអំឡុងសិក្ខាសាលាលោកបណ្ឌិត **យ៉ង សាំងកុមារ** បានរំឭកឡើងវិញអំពីប្រវត្តិនៃការរៀបចំផែនការយុទ្ធសាស្ត្រដែលបានធ្វើរួចចំនួន ២ លើកកន្លងមក រួមមានផែនការឆ្នាំ ២០០៣-២០០៧ និង ២០០៦-២០១០ ព្រមទាំងផែនការរំកិលឆ្នាំ ២០០៨-២០១២។ លោកថា ផែនការ ២០០៦-២០១០ វាជិតចប់ហើយ ដែលវាជាពេលវេលាមួយ សមស្របក្នុងការគិតសម្រាប់ ៣ ទៅ ៥ ឆ្នាំខាងមុខទៀត ដើម្បីដឹងអំពីអ្វីដែលត្រូវធ្វើ? ការបែងចែកនូវតួនាទី និងការទទួលខុសត្រូវ ។ បន្ទាប់មកលោកបណ្ឌិត **យ៉ង សាំងកុមារ** ក៏បានរំលឹកអំពីប្រវត្តិរបស់ សេដាក ផងដែរ ។